គ្រីស្ទសាសនាគឺមិនមែនជាទេវវិទ្យានោះទេ តែជាដំណឹងល្អវិញ។ វាដូចជា អ្នកទោស នៃសង្គ្រាមដែលស្តាប់លឺតាមវិទ្យុសំងាត់ថាក្រុមសម្ព័ន្ធមិត្តបានចុះសំចត ហើយការរំដោះនោះនឹងកើតមានឡើងប៉ុន្តែគឺគ្រាន់ ត្រូវការពេលវេលា តែប៉ុណ្ណោះ។ អ្នកយាមមានការងឿងឆ្ងល់ថាហេតុអ្វីបានជាអ្នកទាំងអស់នោះមានក្តីអំណរ។ ប៉ុន្តែតើអ្វីទៅជាសេចក្តីល្អចុងក្រោយនៅក្នុងដំណឹងល្អ? អ្វីទាំងអស់បញ្ចប់ដោយការមួយគឺៈ ព្រះជាម្ចាស់ផ្ទាល់។ គ្រប់ទាំងពាក្យនៃដំណឹងល្អនាំទៅដល់ទ្រង់ បើមិនអញ្ចឹងទេ ពាក្យទាំងនោះមិនមែនជាដំណឹងល្អទេ។ ឧទាហរណ៍ ប្រសិនបើសេចក្តីសង្គ្រោះគ្រាន់តែជួយសង្គ្រោះពីស្ថាននរក ហើយមិនមែនសំរាប់ព្រះជាម្ចាស់ទេ នោះវាមិនមែនជាដំណឹងល្អទេ។ ការអត់ទោសមិនមែនជាដំណឹងល្អទេ ប្រសិនបើវាគ្រាន់តែផ្តល់នូវភាពធូរស្បើយពីពិរុទ្ធភាព ហើយមិនបើកផ្លូវនាំទៅដល់ ព្រះជាម្ចាស់នោះ។ ការរាប់ជាសុចរិតមិនមែនជាដំណឹងល្អទេ ប្រសិនបើវាគ្រាន់តែធ្វើឱ្យយើងមានការទទួលស្គាល់ជាផ្លូវ ការនៅចំពោះព្រះជាម្ចាស់ ប៉ុន្តែមិនបាននាំមកនូវការប្រកបជាមួយព្រះជាម្ចាស់ទេនោះ។ ការប្រោសលោះមិនមែនជាដំ ណឹងល្អទេ ប្រសិនបើវាគ្រាន់តែធ្វើឱ្យយើងមានសេរីភាពពីចំណង ប៉ុន្តែមិនបាននាំយើងឱ្យទៅដល់ព្រះជាម្ចាស់ទេនោះ។ ការទទួលជាកូនចិញ្ចឹមមិនមែនជាដំណឹងល្អទេ ប្រសិនបើវាគ្រាន់តែដាក់យើងទៅក្នុងគ្រួសាររបស់ព្រះវរបិតា ប៉ុន្តែមិនដាក់ យើងនៅក្នុងព្រះហស្តទ្រង់នោះ។ នេះជាការសំខាន់។ មនុស្សជាច្រើនហាក់ដូចជាអោបក្រសោបដំណឹងល្អដោយមិនអោបក្រសោបព្រះជាម្ចាស់ទេ។ គ្មានភស្តុតាងពិតប្រាកដទេថាយើងមានចិត្តថ្មីមួយ គ្រាន់តែដោយសារយើងចង់គេចចេញពីស្ថាននរក។ នោះគឺជាសេចក្តី ប៉ងប្រាថ្នាពីធម្មជាត់យ៉ាងល្អឥតខ្ចោះមួយ ប៉ុន្តែមិនមែនជាសេចក្តីប៉ងប្រាថ្នាដែលមិនមានអំណាចលើធម្មជាតិនោះទេ។ វា មិនត្រូវការឱ្យមានចិត្តថ្មីមួយនោះទេក្នុងការចង់ឱ្យមានការធូរស្បើយខាងផ្លូវចិត្តនៃការអត់ទោសនោះ ឬការលុបចោល នៃសេចក្តីក្រោធរបស់ព្រះជាម្ចាស់ឬការទទួលលោកិយទាំងមូលរបស់ព្រះជាម្ចាស់ជាមរតក។ សេចក្តីទាំងអស់នេះគឺអាច យល់បានដោយគ្មានការផ្លាស់ប្រែខាងព្រលឹងវិញ្ញាណណាមួយឡើយ។ អ្នកមិនចាំបាច់កើតជាថ្មីឡើយក្នុងការដែលចង់បាន របស់ទាំងនេះ។ អាកំណាចត្រូវការអ្វីទាំងអស់នេះ។ វាមិនមែនខុសនោះទេក្នុងការដែលចង់បានអ្វីទាំងអស់នោះ។ ពិតមែនហើយ វាជាការល្ងីល្ងើដែលមិនចង់បាន របស់ទាំងនោះ។ ប៉ុន្តែភស្តុតាងដែលយើងបានទទួលការផ្លាស់ប្រែនោះ គឺថាយើងចង់បានរបស់ទាំងនេះដោយព្រោះវាអាច នាំយើងទៅដល់ភាពសប្បាយរីករាយរបស់ព្រះជាម្ចាស់។ នេះគឺជាការដ៏អស្ចារ្យបំផុតដែលព្រះគ្រីស្ទបានសុគត។ «ដោយ ព្រោះព្រះគ្រីស្ទបានរងគ្រោះម្តងដោយព្រោះបាបដែរ គឺជាព្រះដ៏សុចរិត ទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនឹងនាំយើង រាល់គ្នាទៅដល់ព្រះ» (១ ពេត្រុស ៣:១៨)។